**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកណ្តាល**
គណៈកម្មាធិការលទ្ធកម្ម
លេខ៖ ..០០៣....សជណ.អល.កណ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង

## ស្តីពីការខារជួសជុលផ្លូវចាក់បេតុងអាមេ ចំនួន៣គម្រោង នៅស្រុកពញាឮ ជូនសាលាខេត្ត

ខេត្តកណ្តាល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនសំណង់ (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាខេត្តកណ្តាលនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលផ្លូវចាក់បេតុងអាមេ ចំនួន៣គម្រោង នៅស្រុកពញាឮ ជូន សាលាខេត្ត ៖ ១-ផ្លូវនៅភូមិផ្សារដែកក្រោម ឃុំផ្សារដែក និងភូមិភ្នំបាត ឃុំភ្នំបាត ប្រវែង 1000m x 5m x 0.15m, ២-ផ្លូវ នៅភូមិកំពង់អុស ឃុំកំពង់អុស ប្រវែង 1000m x 5m x 0.15m, ៣-ផ្លូវនៅភូមិពោធិ៍មង្គល និងភូមិព្រែកក្តី ឃុំព្រែកតាទែន ប្រវែង 1000m x 5m x 0.15m ។

ខេត្តកណ្តាលបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តកណ្តាលមានអាសយដ្ឋានស្ថិតក្នុងសាលាខេត្តកណ្តាលចាប់ពីថ្ងៃទី.៣១...ខែឧសភា... ឆ្នាំ២០១៨ តទៅនៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាល យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០៣..... ខែកក្កដា...ឆ្នាំ២០១៨ វេលាម៉ោង ....៨.......និង.០០.....នាទី។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាល តាមអាសយដ្ឋានខាងលើ វេលាម៉ោង...៨.....និង.០០.....នាទី ថ្ងៃទី .០៣.... ខែ កក្កដា.... ឆ្នាំ២០១៨ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាលដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ .ព្រហ.១.៦រោច.... ខែជេស្ឋ...ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
កណ្តាល ថ្ងៃទី .៣១....ខែ.ឧសភា.....ឆ្នាំ ២០១៨
**អភិបាល នៃគណៈអភិបាលខេត្ត**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

ម៉ៅ ភិរុណ

ចម្លងជូន ÷
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ